**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១៥២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១/ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះក្រមលេខ នស/ រកម/ ០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/ ១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/ ០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០៦១១/ ០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់អំពីអត្រាជាភាគរយនៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដែលត្រូវផ្ទេរប្រចាំឆ្នាំជូនមូលនិធិក្រុង ស្រុក និងរូបមន្ត សន្ទស្សន៍នៃការបែងចែកមូលនិធិក្រុង ស្រុក ព្រមទាំងកម្មវិធីនៃការផ្ទេរឥណទាននិងសាច់ប្រាក់ទៅឱ្យរដ្ឋបាលក្រុង ស្រុក សម្រាប់ចីរវេលា ០៥(ប្រាំ)ឆ្នាំ ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨។

**មាត្រា២.-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើរដ្ឋបាលក្រុង ស្រុកទាំងអស់ទូទាំងប្រទេស។

## ជំពូកទី២

## ប្រភពធនធាន

**មាត្រា៣.-**

កម្រិតនៃការផ្ទេរធនធានពីថវិការដ្ឋទៅក្នុងគណនីមូលនិធិក្រុង ស្រុក ត្រូវកំណត់សម្រាប់ចីរវេលា ០៥ (ប្រាំ)ឆ្នាំ ដោយកំណត់ជាភាគរយនៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដូចខាងក្រោម÷

- ឆ្នាំថវិកា២០២៤: ចំនួន១,៦ភាគរយនៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដែលបានអនុម័តឆ្នាំ២០២៣



ឯកសារផ្លូវការ: | https://t.me/oa_channel

- ឆ្នាំថវិកា២០២៥: ចំនួន ១,៦ភាគរយនៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដែលបានអនុម័តឆ្នាំ២០២៤
- ឆ្នាំថវិកា២០២៦ : ចំនួន ១,៦ភាគរយនៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដែលបានអនុម័តឆ្នាំ២០២៥
- ឆ្នាំថវិកា២០២៧: ចំនួន ១,៦ភាគរយនៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដែលបានអនុម័តឆ្នាំ២០២៦
- ឆ្នាំថវិកា២០២៨: ចំនួន ១,៦ភាគរយនៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដែលបានអនុម័តឆ្នាំ២០២៧។

## ជំពូកទី៣

## ការបែងចែក ការផ្ទេរ និងការប្រើប្រាស់ធនធានមូលនិធិក្រុង ស្រុក

**មាត្រា៤._**

ធនធានមូលនិធិក្រុង ស្រុកត្រូវចែកចេញជាបីសមាសភាគដូចខាងក្រោម÷

- សមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ
- សមាសភាគសេវាសង្គម និងអនាម័យបរិស្ថាន និង
- សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន។

ទំហំធនធាននៃសមាសភាគនីមួយៗនៃមូលនិធិក្រុង ស្រុក ត្រូវកំណត់ដូចខាងក្រោម÷

ក). ទំហំធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ ត្រូវបានកំណត់ដោយផ្អែកលើឯកតារង្វាស់និងនិយាមដូចខាងក្រោម÷

- ចំនួនសរុបនៃសមាជិកក្រុមប្រឹក្សាក្រុង ស្រុក និងប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក
- ចំនួនសរុបនៃអភិបាល អភិបាលរង និងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក និងប្រាក់បៀវត្សសម្រាប់ប្រភេទនីមួយៗ និង
- គម្រោងចំណាយប្រតិបត្តិការរដ្ឋបាលផ្សេងៗទៀតមិនឱ្យលើសពី ២៥ភាគរយ នៃធនធានមូលនិធិសរុប *ដក* ចំណាយសរុបសម្រាប់ប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក និងប្រាក់បៀវត្សរបស់អភិបាល អភិបាលរង និងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក។

ខ). ទំហំធនធាននៃសមាសភាគសេវាសង្គម និងអនាម័យបរិស្ថាន ត្រូវបានកំណត់ស្មើនឹង ២០ ០០០ លានរៀល ក្នុងឆ្នាំនីមួយៗ សម្រាប់ថិរវេលា ០៥(ប្រាំ)ឆ្នាំ ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨។ មុខសញ្ញាចំណាយសម្រាប់សេវាសង្គម និងអនាម័យបរិស្ថាន ត្រូវកំណត់ដោយសេចក្តីណែនាំរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។

គ). ទំហំធនធាននៃសមាភាគអភិវឌ្ឍន៍មូលដ្ឋាន ស្មើនឹងទំហំធនធាននៃមូលនិធិក្រុង ស្រុកសរុប *ដក* ទំហំធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ និងទំហំធនធាននៃសមាសភាគសេវាសង្គម និងអនាម័យបរិស្ថាន។

មាត្រា៥._

ធនធានសមាសភាគទាំងបីនៃមូលនិធិក្រុង ស្រុក ត្រូវបានវិភាជទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗ តាមការគណនាដោយផ្អែកលើរូបមន្ត និងសន្ទស្សន៍ដូចខាងក្រោម ÷

១). ធនធានសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ ត្រូវបានវិភាជទៅរដ្ឋបាលក្រុង ស្រុកនីមួយៗ ដោយអនុលោមតាមនិយាមដូចខាងក្រោម÷

ក). ចំណាយសម្រាប់ប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក

ខ). ចំណាយសម្រាប់ប្រាក់បៀវត្សរបស់អភិបាល អភិបាលរងនៃគណៈអភិបាលក្រុង ស្រុក

គ). ចំណាយសម្រាប់ប្រាក់បៀវត្សរបស់បុគ្គលិករដ្ឋបាលក្រុង ស្រុក ផ្អែកតាមចំនួនបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ

ឃ). ចំណាយសម្រាប់ប្រតិបត្តិការរដ្ឋបាលផ្សេងៗ ត្រូវបែងចែកទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗ តាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម÷

- ចំនួន ៤០ភាគរយ ជាចំណែកស្មើគ្នា ត្រូវបានបែងចែកក្នុងទំហំចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាលក្រុង ស្រុកនីមួយៗ
- ចំនួន ៣០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនសមាជិកក្រុមប្រឹក្សា និងចំនួនសមាជិកគណៈអភិបាលនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ
- ចំនួន ៣០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ ។

២). ធនធានសមាសភាគសេវាសង្គម និងអនាម័យបរិស្ថាន ត្រូវបានវិភាជទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗតាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម÷

ក). ចំនួន ៣០ភាគរយ ជាចំណែកស្មើគ្នា ត្រូវបានបែងចែកក្នុងទំហំចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាលក្រុង ស្រុកនីមួយៗ

ខ). ចំនួន ២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនប្រជាជននៃរដ្ឋបាលក្រុង ស្រុកនីមួយៗ ដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ

គ). ចំនួន ៥០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃសន្ទស្សន៍ភាពក្រីក្រដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ។

៣). ធនធានសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ត្រូវបានវិភាជទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗតាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម÷



គេហទំព័រ ឯកសារផ្លូវការ: | https://t.me/oa_channel

ក).ចំនួន ៤០ភាគរយ ជាចំណែកស្មើគ្នា ត្រូវបានបែងចែកក្នុងទំហំចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាលក្រុង ស្រុកនីមួយៗ

ខ).ចំនួន ២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនប្រជាជននៃរដ្ឋបាលក្រុង ស្រុកនីមួយៗដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ

គ).ចំនួន ៤០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃសន្ទស្សន៍ភាពក្រីក្រដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ។

**មាត្រា៦._**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបោះផ្សាយអាណត្តិឧបត្ថម្ភធនជូនមូលនិធិក្រុង ស្រុកជា ០៤(បួន) លើកសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំតាមកម្មវិធីដូចខាងក្រោម÷

- លើកទី១ : ផ្ទេរ ២៥ភាគរយនៃធនធានមូលនិធិសរុបនៅដើមត្រីមាសទី១
- លើកទី២ : ផ្ទេរ ២៥ភាគរយនៃធនធានមូលនិធិសរុបនៅដើមត្រីមាសទី២
- លើកទី៣ : ផ្ទេរ ២៥ភាគរយនៃធនធានមូលនិធិសរុបនៅដើមត្រីមាសទី៣
- លើកទី៤ : ផ្ទេរ ២៥ភាគរយនៃធនធានមូលនិធិសរុបនៅដើមត្រីមាសទី៤។

**មាត្រា៧._**

រដ្ឋបាលក្រុង ស្រុក អាចប្រើប្រាស់ធនធានដែលផ្ទេរពីមូលនិធិក្រុង ស្រុក ដើម្បីផ្ដល់ហិរញ្ញប្បទានដល់ចំណាយសមាសភាគណាមួយបាន លុះត្រាតែចំណាយទាំងនោះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងថវិការបស់រដ្ឋបាលក្រុង ស្រុក ដែលបានអនុម័ត និងមិនផ្ទុយនឹងច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិដែលមានការពាក់ព័ន្ធជាធរមាន។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា៨._**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ក្រុមប្រឹក្សាខេត្ត អភិបាលនៃគណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក និងអភិបាលនៃគណៈអភិបាលក្រុង ស្រុកទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃចន្ទ ៨ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២៣ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល</u>**÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



តេលេក្រាម ឯកសារផ្លូវការណ៍: | https://t.me/oa_channel